# មគ្គុទ្ទេសក៍យោងសង្ខេបរហ័ស

**សំណើ 50** **អនុញ្ញាតឱ្យមានការផ្លាស់ប្តូរជាបណ្តោះអាសន្នលើផែនទីតំបន់តំណាងសភា ដើម្បីឆ្លើយតបចំពោះការបែងចែកតំបន់ សារឡើងវិញរបស់រដ្ឋ TEXAS តាមផ្អែកលើគណបក្ស។ ការកែប្រែរដ្ឋធម្មនុញ្ញដោយសភានីតិបញ្ញត្តិ។**

សេចក្តីសង្ខេប *ដាក់លើសន្លឹកឆ្នោតដោយអង្គនីតិបញ្ញត្តិ*

តម្រូវឱ្យប្រើផែនទីតំបន់តំណាងសភាថ្មីជាបណ្តោះអាសន្នរហូតដល់ឆ្នាំ 2030។ បញ្ជាឱ្យគណៈកម្មការបែងចែកតំបន់ឯករាជ្យរបស់ពលរដ្ឋបន្ត អនុម័តផែនទីតំបន់តំណាងសភាឡើងវិញក្នុងឆ្នាំ 2031។ បង្កើតគោលនយោបាយគាំទ្រគណៈកម្មការបែងចែកតំបន់សារឡើងវិញ តំណាងសភាដែលមិនផ្អែកលើគណបក្ស នៅទូទាំងប្រទេស។ ផលប៉ះ**ពាល់សារពើពន្ធ៖** ការចំណាយតែមួយលើកសម្រាប់មូលដ្ឋានឆ្នោត អាចមានចំនួនរហូតដល់ពីរបីលានដុល្លារ ទូទាំងរដ្ឋ ដើម្បីកែប្រែឯកសារបោះឆ្នោត ឲ្យឆ្លុះបញ្ចាំងផែនទីតំបន់តំណាងសភាថ្មី។

## ការបោះឆ្នោតរបស់អ្នកមានសារៈសំខាន់អ្វីខ្លះ

**បាទ**/ចាស បោះឆ្នោតគាំទ្រលើវិធានការនេះមានន័យថា៖ រដ្ឋនឹងប្រើផែនទីតំបន់តំណាងសភាដែលបានគូសថ្មីចាប់ពីឆ្នាំ 2026 តទៅ។ ផែនទីថ្មីរបស់រដ្ឋ California នឹងត្រូវបានប្រើរហូតដល់គណៈកម្មការបែងចែកតំបន់សារឡើងវិញរបស់ពលរដ្ឋនៅរដ្ឋ California គូសផែនទីថ្មីបន្ទាប់ពីជំរឿនសហរដ្ឋអាមេរិកឆ្នាំ 2030។

**ទេ** បោះឆ្នោតប្រឆាំងនឹងវិធានការមានន័យថា៖ ផែនទីតំបន់តំណាងសភាបច្ចុប្បន្នដែលគូសដោយគណៈកម្មការបែងចែកតំបន់សារឡើងវិញរបស់ពលរដ្ឋនៅរដ្ឋ California (គណៈកម្មការ) នឹងត្រូវបានបន្តប្រើនៅក្នុងរដ្ឋ California រហូតដល់គណៈកម្មការគូសផែនទីថ្មីបន្ទាប់ពីជំរឿនសហរដ្ឋអាមេរិកឆ្នាំ 2030។

## ទឡ្ហីករណ៍

**គាំទ្រ** សំណើទី 50—ច្បាប់ស្តីពីការឆ្លើយតបនឹងការលួចបន្លំសន្លឹកឆ្នោត—យល់ព្រមលើផែនទីតំបន់តំណាងសភាបណ្តោះអាសន្នបន្ទាន់ ដើម្បីប្រឆាំងនឹងផែនការរបស់លោក Donald Trump ក្នុងការលួចបន្លំការបោះឆ្នោតសភានៅឆ្នាំបន្ទាប់ និងអះអាងជាថ្មីអំពីការប្តេជ្ញារបស់រដ្ឋ California ចំពោះការបែងចែកតំបន់សារឡើងវិញដោយឯករាជ្យមិនចូលខាងគណបក្សណាមួយ នៅក្រោយជំរឿនបន្ទាប់។ បោះឆ្នោតគាំទ្រលើសំណើទី 50 ដើម្បីប្រជាធិបតេយ្យនៅក្នុងរដ្ឋទាំង 50។ ស្វែងយល់បន្ថែមតាមរយៈ *StopElectionRigging.com*។

**ប្រឆាំង** សំណើទី 50 ត្រូវបានសរសេរឡើងដោយអ្នកនយោបាយ ដើម្បីអ្នកនយោបាយ—ដកចេញនូវការការពារដែលរក្សាការបោះឆ្នោតឱ្យមានភាពយុត្តិធម៌ ដកចេញនូវលក្ខខណ្ឌតម្រូវក្នុងការរក្សាសហគមន៍មូលដ្ឋានជាមួយគ្នា និងលុបបំបាត់ការការពារអ្នកបោះឆ្នោតដែលហាមឃាត់ផែនទីដែលរៀបចំ ដើម្បីផ្តល់ប្រយោជន៍ដល់គណបក្សនយោបាយ។ បោះឆ្នោតប្រឆាំងដើម្បីការពារការបោះឆ្នោតប្រកបដោយយុត្តិធម៌ និងរក្សាប្រជាជនដែលទទួលបន្ទុកក្នុងការបែងចែកតំបន់ឡើងវិញ មិនមែនអ្នកនយោបាយនោះទេ។

## សម្រាប់ព័ត៌មានបន្ថែម

**សម្រាប់**
អភិបាល Gavin Newsom
គាំទ្រលើសំណើទី 50 ច្បាប់ស្តីពីការឆ្លើយតបនឹងការលួចបន្លំសន្លឹកឆ្នោត
គណៈកម្មាធិការវិធានការសន្លឹកឆ្នោតរបស់អភិបាល Newsom
555 Capitol Mall, Suite 400
Sacramento, CA 95814
info@stopelectionrigging.com
StopElectionRigging.com

**ប្រឆាំង**
ប្រឆាំងនឹងសំណើទី 50—ការពារអ្នកបោះឆ្នោតជាអាទិភាព គាំទ្រដោយឱ្យអ្នកនយោបាយទទួលខុសត្រូវ
2350 Kerner Blvd., Suite 250
San Rafael, CA 94901
(916) 446-6572
info@votersfirstact.org
VotersFirstAct.org

# ព័ត៌មានថ្ងៃបោះឆ្នោត

ទីតាំងបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ នៅថ្ងៃអង្គារ ទី 4 ខែវិច្ឆិកា ឆ្នាំ 2025។ ប្រសិនជាអ្នកកំពុង តម្រង់ជួរមុនម៉ោង 8:00 យប់ អ្នកនៅតែអាចបោះឆ្នោតបាន។

# ស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក ឬមជ្ឈមណ្ឌលបោះឆ្នោត

កន្លែងបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវបានបង្កើតឡើងដោយមន្ត្រីរៀបចំការបោះឆ្នោតខោនធី។ សូមរកមើលអាសយដ្ឋានកន្លែងបោះឆ្នោតរបស់អ្នក ឬទីតាំងមណ្ឌលបោះឆ្នោតនៅក្នុងមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតតាមខោនធីដែលអ្នកបានទទួលតាមសំបុត្រពីរបីសប្តាហ៍មុនថ្ងៃបោះឆ្នោត។

អ្នកក៏អាចចូលទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការនៅតាមរយៈ *vote.ca.gov* ឬហៅទូរសព្ទទៅលេខទូរសព្ទអ្នកបោះឆ្នោតដោយមិនគិតថ្លៃរបស់យើងតាមលេខ (888) 345-4917។




លទ្ធផលបោះឆ្នោតសម្រាប់ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូលនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025 គឺអាចរកបាន បន្ទាប់ពីការបោះឆ្នោតបិទនៅម៉ោង 8:00 យប់ នៅលើគេហទំព័រលទ្ធផលការបោះឆ្នោតរបស់រដ្ឋលេខាធិការនៃរដ្ឋ California តាមរយៈ *electionresults.sos.ca.gov*។

លទ្ធផលនឹងចាប់ផ្តើមប្រកាសនៅម៉ោង 8:00 យប់ ហើយនឹងត្រូវបានធ្វើបច្ចុប្បន្នពេញមួយយប់នៃការបោះឆ្នោត។ នៅថ្ងៃបន្ទាប់ លទ្ធផលនឹងធ្វើបច្ចុប្បន្នភាពនៅម៉ោង 5:00 ល្ងាច រៀងរាល់ថ្ងៃពេញមួយ canvass ខណៈដែលខោនធីរាប់សន្លឹកឆ្នោតសេសសល់។

លទ្ធផលដែលបានបញ្ជាក់ជាផ្លូវការនៃការបោះឆ្នោតនឹងត្រូវប្រកាសត្រឹមថ្ងៃទី 12 ខែធ្នូ ឆ្នាំ 2025 តាមរយៈ *sos.ca.gov/elections*។